# ដំណាំននោង

## I. ស្ថានភាពទូទៅ

ននោងជាដំណាំប្រពៃណីមួយដែលដុះ និងលូតលាស់ពេញមួយឆ្នាំ ហើយវាមានលទ្ធភាពវារតោងឡើងតាមដើមរុក្ខជាតិដទៃទៀត ដោយភាពវល្លិ៍របស់ដើម ។ ដំណាំនេះ ត្រូវបានគេជឿជាក់ថាវាមានអាយុយ៉ាងចំណាស់នៅលើផែនដីយើងជាង ៣០០០ឆ្នាំមកហើយបើតាមការស្រាវជ្រាវរបស់អ្នកវិទូនៅមជ្ឈមណ្ឌលស្រាវជ្រាវរុក្ខជាតិនៅទ្វីបអាហ្វ្រិក និងអាស៊ី ។ តាមប្រវត្តិនៃការដាំដុះដ៏យូរអង្វែងរបស់វា គឺគេកំណត់ថាវាមានប្រភពដើមនៅក្នុងតំបន់ក្តៅគឺអាស៊ី អាហ្វ្រិក ។ លក្ខណៈរុក្ខសាស្ត្រដើមជាវល្លិ៍ ផ្កាច្រើនស្រទាប់មានពណ៌លឿងផ្លែពី ១៥-២០ ផ្លែក្នុង មួយដើម ផ្លែសំបូរដោយសារធាតុចិញ្ចឹមច្រើនមុខ និងពេញនិយមសម្រាប់អ្នកបរិភោគថែមទៀតផង ។





### តារាងតំលៃអាហារូបត្ថម្ភ

**ទម្ងន់ ១០០ ក្រាម ចុបបាន (ផ្លែ ស្ងួត) មានសារធាតុចិញ្ចឹម :**

| សារធាតុចិញ្ចឹម | ទម្ងន់ | ផ្លែ | ស្ងួត |
|---|---|---|---|
| ថាមពល | កាឡូរី | ១០ | ២៧ |
| ប្រូតេអ៊ីន | ក្រ | ១.១ | ៥.១ |
| ខ្លាញ់ | ក្រ | ០.២ | ០០ |
| កាបូនអ៊ីដ្រាត | ក្រ | ៤.០ | ៤.១ |
| ជាតិសរសៃ | ក្រ | ១.០ | ១.៥ |
| ផេះ | ក្រ | ០.៤ | ០.៧ |
| កាល់ស្យូម | មីលីក្រាម | ២ | ៥៦ |
| ផូស្វ័រ | មីលីក្រាម | ៣០ | ១៤០ |
| ដែក | មីលីក្រាម | ០.៧ | ១១.៥ |
| ប៉ូតាស្យូម | មីលីក្រាម | ១៥៤ | ០០ |
| ការ៉ូតែន | µg | ១៧០ | ៥.២៤០ |
| វីតាមីន បេ ១ | មីលីក្រាម | ០.០៣ | ០.០៥ |
| វីតាមីន បេ ២ | មីលីក្រាម | ០.០៤ | ០.០៦ |
| វីតាមីន បេ ៣ | មីលីក្រាម | ០.០៣ | ០០ |
| វីតាមីន សេ | មីលីក្រាម | ១០ | ៥៥ |

## II. អំពីកត្តាដី និងអាកាសធាតុ

អំពីដី និងអាកាសធាតុជាកត្តាចាំបាច់ សម្រាប់ការដាំដុះព្រោះដំណាំនីមួយៗ ត្រូវការប្រភេទដីផ្សេងៗ ពីគ្នានឹងលក្ខខណ្ឌ អាកាសធាតុផ្សេងពីគ្នាដែរ ។

## ១. ការជ្រើសរើសដី និងការរៀបចំដី

ដំណាំសមស្របទៅលើដី ស្ទើរគ្រប់ប្រភេទគេអាចដាំវាលើប្រភពដីជូរ និង ដីប្រៃ ចំពោះ pH ចន្លោះពី ៤,៥-៨,៥ ហើយវាអាចធានាការសើមខ្លាំងរបស់ ដីរហូតដល់រយៈពេលលូតលាស់វែងស្ទើរពេលមួយឆ្នាំ ។ គេអាចដាំលើដីទំនាប់ដូចជាដីស្រែបានគ្រាន់តែលើទួលផុតពីទឹកកំពស់ ១០-១៥ ស.ម ។





ចំពោះការរៀបចំដីគឺ គួរតែភ្ជួរឱ្យបានជ្រៅជម្រៅពី ២០-៣០ ស.ម ហើយរាស់បំបែកដីឱ្យម៉ត់ទើបលើករងឱ្យមាន ទទឹងរង ១០០-១២០ ស.ម កំពស់ពី ២៥-៣០ស.ម ។ ដើម្បីងាយស្រួលធ្វើផ្នើរឱ្យដំណាំវារតោងឡើង គេត្រូវធ្វើឱ្យឃ្លាតពីរងមួយទៅរងមួយ ៣-៣,៥ ម ។មុនលើករងគេយកជីធម្មជាតិ និង ជីគីមីទៅដាក់ហើយពូនលុបឱ្យជិតដើម្បីឱ្យអាចរក្សាសំណើមនិងជីជាតិបានយូរ ។

## ២. លក្ខខណ្ឌអាកាសធាតុ

វាត្រូវការសីតុណ្ហភាពក្តៅពី ២៥-៣៥ °C ដើម្បីដុះលូតលាស់ និងបង្កបង្កើតផ្លែ ។ វាពុំត្រូវការសីតុណ្ហភាពដែលទាបជាង ១៨ °C ឡើយ ព្រោះធ្វើឱ្យគ្រាប់របស់វាមិនអាចដុះលូតលាស់បាន ពេលចេញផ្កា ធ្វើឱ្យផ្កាជ្រុះ និងបាត់បង់បរិមាណផលយ៉ាងច្រើន ។ ដំណាំប្រភេទ នេះមិនត្រូវការខ្យល់បក់ខ្លាំងនោះឡើយព្រោះធ្វើឱ្យការបោះទងលូតមិនបានល្អ ។ ចំពោះសំណើមបរិយាកាសវិញសមស្របគឺស្ថិតក្នុងចន្លោះពី ៧០-៨៥% ។



## III. វិធីសាស្ត្រដាំដុះ

មុននឹងធ្វើការដាំដុះគេគួរតែធ្វើការជ្រើសរើសពូជជាមុន ព្រោះពូជខ្លះប្រកាន់រដូវ ពូជខ្លះមិនប្រកាន់រដូវគេអាចដាំននោងបាន ២របៀប អាស្រ័យទៅលើចំណង់ចំណូលចិត្ត និងលក្ខខណ្ឌ បរិស្ថាន ចំពោះការដាំជាលក្ខណៈគ្រួសារគេច្រើនដាំដោយគ្រាប់ផ្ទាល់ឬដោយកូនបណ្ដុះ តែចំពោះការដាំលក្ខណៈផលិតកម្មធំៗគឺគេដាំដោយគ្រាប់ផ្ទាល់ជាការងាយស្រួល ។





### ១. ការដាំដោយគ្រាប់ផ្ទាល់

ក្រោយពីការលើករង និងដាក់ជីរួចហើយ គេត្រូវយកគ្រាប់ននោងទៅដាក់ហាលថ្ងៃឱ្យក្ដៅពី ១-២ ម៉ោង ហើយត្រាំទឹករយៈពេល ១យប់ (១២ម៉ោង) ហើយយកទៅផ្អាប់រយៈ ២-៣ ថ្ងៃ ក្រោយពីការដុះពន្លកទើបយកទៅដាំលើរង ដោយកប់ជម្រៅ ៣-៤ ស.ម ហើយដាក់ជីកំប៉ុស្តិ៍ ឬកំណាត់ចំបើងគ្របពីលើទើបស្រោចទឹកតាមក្រោយ ។ចន្លោះគុម្ពមួយទៅមួយប្រមាណពី ២០-៣០ស.ម និងក្នុងមួយគុម្ព ២ដើម ។



## ៤. ការដោតចំណារ ឬ ធ្នើរ

ដំណាំននោង មិនត្រូវដាំដោយឱ្យវារនៅលើដីផ្ទាល់ឡើយ ព្រោះធ្វើឱ្យផ្លែមិនមានលក្ខណៈត្រង់ស្រឡូនត្រូវដាំដោយដោតចំណារ ឬ ធ្នើរ ធ្វើបែបនេះវាអាចដុះលូតលាស់តាមលក្ខណៈរុក្ខសាស្ត្ររបស់ដំណាំ ។ ក្រោយពេលដាំរយៈពេល ១០-១២ ថ្ងៃវាបោះទងចេញដៃសម្រាប់តោងឡើងដូច្នេះគេគួរតែធ្វើនៅពេលនោះជាការប្រសើរ ។ កម្ពស់ធ្នើរត្រូវធ្វើឱ្យផុតពីដីកម្ពស់ ១,៨ - ២,00ម ដើម្បីឱ្យស្រឡះ ខ្យល់ចេញចូលបានល្អការធ្វើបែបនេះគឺអាចការពារពីការបំផ្លាញពីពពួកសត្វល្អិតចង្រៃនិងជម្ងឺផ្សេងៗ ។



## ២. ការដាំដោយបណ្តុះកូន

ក្រោយពីផ្អាប់ដូចករណីទី១ ហើយគេយកទៅបណ្តុះក្នុងកន្ទោង ឬថានរយៈពេល ៤-៥ ថ្ងៃកូនននោងចេញស្លឹកកំណើតទី២ គេអាចយកទៅដាំបាន ។ គេមិនអាចទុកឱ្យននោងចេញស្លឹកពិត ឬចេញផ្កាទើបយកទៅដាំនោះទេ វាធ្វើការលូតលាស់យឺត ។ ចំពោះចន្លោះគុម្ព និងចំនួនដើមដូចគ្នាទៅនឹងករណីខាងលើដែរ ។

## ៣. ការស្រោចស្រព

ននោងត្រូវការទឹកជាងដំណាំឃ្លោក ត្រសក់ និង ល្ពៅ គេអាចបញ្ចូលទឹកឱ្យជោគខ្លាំងក្នុង១សប្តាហ៍អាចពី ២-៣ លើកជាពិសេស នៅពេលចេញផ្កា ។ ពូជស្រាលមិនប្រកាន់រដូវចេញផ្កាអាយុ ២៨-៣២ ថ្ងៃក្រោយដាំ ចំពោះពូជធ្ងន់ ជាពូជប្រកាន់រដូវ វាអាចចេញផ្កានៅពេលវេលាជាក់លាក់ណាមួយរបស់វាដូចជា ពូជក្នុងស្រុកក្នុងកំឡុងពេលពី ៩០ - ១២០ ថ្ងៃក្រោយដាំទើបចេញផ្កាពិសេសនៅចុងឆ្នាំបញ្ចប់រដូវ ។

